## អ្វីដែលត្រូវមានក្នុងដៃរបស់អ្នក
## ត្រៀមខ្លួនជាស្រេចដើម្បីជន្លៀសចេញ

ប្រសិនបើមន្ត្រីប្រាប់អ្នកឱ្យជន្លៀសចេញ អ្នកត្រូវតែចាកចេញ។

នេះគឺជាអ្វីដែលអ្នកត្រូវធ្វើ :

- ធ្វើចិត្តឱ្យត្រជាក់ ។ ធ្វើតាមអ្វីដែលមន្ត្រីប្រាប់អ្នកឱ្យធ្វើ ។
- ប្រសិនបើមានពេល ចូររក្សាសុវត្ថិភាពផ្ទះរបស់អ្នក ។ បិទ និងចាក់សោរបង្អួច និងទ្វារ ។ ដកភ្លើងសម្ភារៈអគ្គិសនីមុនពេលអ្នកចាកចេញ ។ មន្ត្រីនឹងប្រាប់អ្នក ប្រសិនបើអ្នកត្រូវការបិទបណ្តាញទឹកភ្លើង ។
- ចូរឱ្យមិត្តភក្តិ និងសាច់ញាតិដឹងពីកន្លែងដែលអ្នកនឹងទៅ ។
- ចូរពាក់ស្បែកជើងមាំ និងសម្លៀកបំពាក់ការពារ និងងាយស្រួលដូចជា ខោខ្លី និងអាវដៃវែង ។
- ចូរចាប់យកកាតាបធ្វើដំណើរចេញរបស់អ្នក ។
- ចូរកុំប្រើប្រាស់ជណ្តើរយន្ត ពេលមានអគ្គិភ័យ ឬភាពអាសន្ន ផ្សេងទៀត ។
- ចូរបើកវិទ្យុ និង ទូរទស្សន៍ក្នុងតំបន់ ឱ្យដឹងពីផ្លូវជន្លៀសចេញចុងក្រោយបំផុត និងព័ត៌មានផ្សេងទៀត ។
- ចូរទៅកាន់ជម្រក ឬកន្លែងមានសុវត្ថិភាពជិតបំផុត ឱ្យបានឆាប់តាមដែលអ្នកអាច ។

មិនថាតែមន្ត្រីប្រាប់អ្នកឱ្យទៅជ្រកក្នុងកន្លែងមួយ ឬជន្លៀសចេញក៏ដោយ នឹងផ្អែកទៅលើលក្ខខណ្ឌដែលបានរំពឹងទុកក្នុងតំបន់របស់អ្នក ។ ប្រសិនបើអ្នកមិនបានទទួលការណែនាំជាក់លាក់ ដើម្បីជន្លៀសចេញ អ្នកគួរតែទៅជ្រកក្នុងកន្លែងមួយ ។



## ចូរចាប់យកកាតាបធ្វើដំណើររបស់គ្រួសារអ្នក



រៀបចំកាតាបធ្វើដំណើរសម្រាប់វត្ថុប្រើប្រាស់ក្នុងគ្រួសាររបស់អ្នក អ្នកនឹងត្រូវការ ប្រសិនបើមន្ត្រីប្រាប់អ្នកឱ្យជន្លៀសចេញ។ កាតាបធ្វើដំណើររបស់អ្នក គួរតែមានភាពងាយស្រួល–កាន់ – ជាកាតាបស្ពាយខ្នង ឬវ៉ាលីសមានកង់តូចមួយ ។ ចូររក្សា កាតាបធ្វើដំណើររបស់អ្នក ក្នុង–កន្លែងមួយ ដែលអ្នកអាចយកវាងាយស្រួល ក្នុងករណីអ្នកត្រូវចាកចេញបន្ទាន់ ។

វត្ថុសម្រាប់កាតាបធ្វើដំណើររបស់អ្នក :

- សំណៅចម្លងឯកសារសំខាន់ៗរបស់អ្នកដូចជា ប័ណ្ណធានារ៉ាប់រង អត្តសញ្ញាណប័ណ្ណមានរូបថត សំបុត្រកំណើត ប័ណ្ណកម្មសិទ្ធិ និង ភស្តុតាងបញ្ជាក់ពីអាសយដ្ឋាន ក្នុងប្រអប់មិនជ្រាបទឹក និងអាចយកតាមខ្លួនបាន ។
- ឡាន និងសោផ្ទះ ។
- ក្រេឌីតកាត និងអេធីអុីមកាត ។
- ប្រាក់ ជាពិសេសក្រដាសប្រាក់តូចៗដូចជាមួយដុល្លារ ប្រាំដុល្លារ និងដប់ដុល្លារ ។
- ទឹកក្នុងដប និងចំណីអាហារដែលនឹងមិនងាយខូចដូចជាដុំអាហារផ្តល់ថាមពល និងហ្គ្រាណូឡា ។
- ពិល និងថ្មពិលបន្ថែម ។
- វិទ្យុប្រើប្រាស់ថ្មពិល និងថ្មពិលបន្ថែម អ្នកក៏អាចទិញវិទ្យុដែលមិនប្រើថ្មពិលផងដែរ )
- ថ្នាំពេទ្យ : ចូរច្បាស់ថាបានដាក់បំពេញថ្នាំពេទ្យឡើងវិញ មុនពេលពួកវាអស់ ។ ចូររក្សាបញ្ជីឱសថ ដែលសមាជិកគ្រួសាររបស់អ្នកម្នាក់ៗលេប ហេតុអ្វីបានពួកគេលេប និងចំនួនប្រើប្រាស់របស់ពួកគេ ។ ក៏សូមរក្សាសំណៅចម្លងវេជ្ជបញ្ជា និងព័ត៌មានទំនាក់ទំនងគ្រូពេទ្យ និងឱសថការីរបស់អ្នកផងដែរ។
- ឧបករណ៍ជំនួយបឋម ។
- ស្បែកជើងមាំ ងាយស្រួល សម្ភារៈទប់ទល់ទឹកភ្លៀងទម្ងន់ស្រាល និងភួយមីឡា ។
- ព័ត៌មាន និងកន្លែងជួបគ្នាសម្រាប់គ្រួសាររបស់អ្នក ។
- ផែនទីតំបន់តូចមួយ ។
- វត្ថុថែទាំផ្ទាល់ខ្លួន : ឧបករណ៍ថែរក្សាអនាម័យដៃ ផលិតផលស្ត្រី ច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញ និងក្រណាត់សំអាត ។
- សម្ភារៈផ្គត់ផ្គង់ថែទាំកុមារ និងសម្ភារៈថែទាំពិសេសផ្សេងទៀត ។

សម្រាប់ព័ត៌មានបន្ថែម អំពីអ្វីដែលត្រូវធ្វើក្នុងកំឡុងពេលមានភាពអាសន្ន សូមចូលទៅកាន់

www.phila.gov/ready,
ឬទូរស័ព្ទទៅលេខ
1-877-READY-11

TheStarGroup

READY PHILADELPHIA Or Not? American Red Cross

The Inquirer DAILY NEWS philly.com

Cambodian



# READY PHILADELPHIA Or Not?

កម្មវិធីត្រៀមខ្លួនសម្រាប់អាសន្ន (Emergency Preparedness Program)

សម្រាប់តំបន់ហ្វីឡាដែលហ្វៀ

អ្វីដែលត្រូវមាននៅក្នុងក្បាលរបស់អ្នក

អ្វីដែលត្រូវមាននៅក្នុងផ្ទះរបស់អ្នក

អ្វីដែលត្រូវមាននៅក្នុងដៃរបស់អ្នក

## យើងចង់ឱ្យអ្នកត្រៀមខ្លួនជាស្រេច សម្រាប់ភាពអាសន្នណាមួយ

នេះគឺជាអ្វីដែលអ្នកត្រូវការឱ្យមាននៅក្នុង
ក្បាលរបស់អ្នក
ក្នុងផ្ទះរបស់អ្នក
និងក្នុងដៃរបស់អ្នក ។

ការធ្វើផែនការនាពេលនេះ និងការដឹងពី អ្វីដែលត្រូវធ្វើ នឹងធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់អ្នក និងគ្រួសាររបស់អ្នក ប្រសិនបើមានភាពអាសន្នកើតមានឡើង ។

ចូរគិតអំពីថាតើភាពអាសន្នអាចប៉ះពាល់អ្នកដូចម្តេចខ្លះ ។ ចូរគិតអំពីធនធាន និងសម្ភារៈផ្គត់ផ្គង់អ្វីខ្លះដែលអ្នកប្រហែលជាត្រូវការ ។ ចូរគិតអំពីប្រភេទ នៃភាពអាសន្នផ្សេងៗ – ភ្លើងឆេះផ្ទះ ព្យុះព្រិល គ្មានអគ្គីសនី ខ្យល់ព្យុះ ឬការវាយប្រហារភេរវកម្ម ។ ចូរបង្កើតផែនការដែលសមរម្យនឹងតម្រូវការរបស់អ្នក និងងាយស្រួលដាក់អនុវត្ត ។

ត្រៀមជាស្រេចដើម្បី ជ្រកក្នុងកន្លែងមួយ ។
ត្រៀមជាស្រេចដើម្បី ជន្លៀសចេញ ។

## តើអ្នកត្រៀមរួចឬនៅ ?



## អ្វីដែលត្រូវមានក្នុងក្បាលរបស់អ្នក ផែនការអាសន្នរបស់អ្នក



ពិភាក្សាជាមួយគ្រួសាររបស់អ្នកអំពីភាពអាសន្ន: អ្វីដែលត្រូវធ្វើ វិធីស្វែងរកគ្នាទៅវិញទៅមកនិង វិធីទាក់ទងជាប់ជានិច្ចក្នុងពេលមានភាពអាសន្ន ។

ចូរត្រៀមជាស្រេច ដើម្បីជ្រកក្នុងកន្លែងមួយយ៉ាងហោចណាស់ ៧២ ម៉ោង ។ ប្រសិនបើមន្ត្រីប្រាប់អ្នក ចូរត្រៀមជាស្រេចដើម្បីជន្លៀសចេញ ។

ចូរសម្រេចពីកន្លែងពីរដែលសមាជិកគ្រួសារគួរតែជួបគ្នា បន្ទាប់ពីមានភាពអាសន្ន – មួយនៅខាងក្រៅ ឬក្បែរផ្ទះរបស់អ្នក និងមួយនៅខាងក្រៅសង្កាត់របស់អ្នក ។

ចូរអនុវត្តការចេញក្រៅផ្ទះរបស់អ្នក ដោយប្រើប្រាស់ទ្វារផ្សេងៗ។ ចូរអនុវត្តការទៅកាន់កន្លែងជួបគ្នារបស់អ្នក ។

ចូរស្នើមិត្តភក្តិ ឬសាច់ញាតិដែលរស់នៅក្រៅរដ្ឋ ដើម្បីទាក់ទងពេលមានអាសន្នរបស់គ្រួសារអ្នក ។ ប្រសិនបើ ខ្សែទូរស័ព្ទហ្វីឡាដែលហៀជាប់រវល់ ការទូរស័ព្ទរយៈចម្ងាយឆ្ងាយ អាចនឹងងាយស្រួលទូរស័ព្ទជាង ។

ចូរធ្វើផែនការសម្រាប់គ្រប់ៗគ្នានៅក្នុងគ្រួសាររបស់អ្នក – ជាពិសេសមនុស្សចាស់ មនុស្សពិការ និងមនុស្សដែលមិននិយាយភាសាអង់គ្លេស ។

ចូរផ្តល់ឱ្យគ្រប់ៗគ្នាក្នុងផ្ទះរបស់អ្នក នូវផែនការភាពអាសន្នរបស់អ្នកមួយច្បាប់ និងព័ត៌មានទាក់ទងពេលមានភាពអាសន្ន ដើម្បីទុកក្នុងកាបូបប្រាក់ និងកាតាបស្ពាយរបស់ពួកគេ ។

ពីរដងក្នុងមួយឆ្នាំ :

- ផ្លាស់ប្តូរថ្មពិលប្រកាសអាសន្នឆេះរបស់អ្នកចេញ
- ធ្វើឱ្យច្បាស់ថា ផែនការភាពអាសន្នរបស់អ្នក និងព័ត៌មានទាក់ទងពេលមានភាពអាសន្នត្រឹមត្រូវ ។
- ពិនិត្យមើលថា ចំណីអាហារ និងថ្មពិលក្នុងឧបករណ៍របស់អ្នកនៅតែល្អ ។

## អ្វីដែលត្រូវមានក្នុងផ្ទះរបស់អ្នក ចូរត្រៀមជាស្រេចដើម្បីជ្រកក្នុងកន្លែងមួយ

ប្រសិនបើមន្ត្រីប្រាប់អ្នកឱ្យជ្រកក្នុងកន្លែងមួយ អ្នកត្រូវតែនៅខាងក្នុងអាគារណាមួយ ។

ដាក់រួមគ្នានូវឧបករណ៍ជ្រកក្នុងកន្លែងមួយ ។ ចូរដាក់បញ្ចូលនូវសម្ភារៈផ្គត់ផ្គង់សម្រាប់យ៉ាងហោចណាស់បីថ្ងៃ ក្នុងករណីអ្នកមិនអាចចាកចេញពីផ្ទះរបស់អ្នកបាន ។

វិធីជ្រកក្នុងកន្លែងមួយ :

- ធ្វើចិត្តឱ្យត្រជាក់ និងទៅខាងក្នុងជាបន្ទាន់ ។
- ទៅកាន់បន្ទប់ដែលមានទ្វារ ឬបង្អួចច្រើន ។ យកល្អបន្ទប់គួរតែស្ថិតនៅខ្ពស់ជាងផ្លូវ មានបន្ទប់សម្រាប់គ្រប់ៗគ្នាក្នុងគ្រួសាររបស់អ្នក មានទឹក និងសម្ភារៈបន្ទប់ទឹកប្រើប្រាស់ ហើយមានតម្លើងទូរស័ព្ទ ។
- បិទ និងចាក់សោបន្ទប់ និងទ្វារទាំងអស់ ហើយបិទសន្ទះខ្យល់ ជើងក្រានកំដៅផ្ទះ ។
- ចូរបិទទ្វារ និងបង្អួច តែនៅពេលដែលត្រូវបានប្រាប់ឱ្យធ្វើដូច្នេះដោយមន្ត្រីភាពអាសន្ន ។ ប្រសិនបើត្រូវបានណែនាំ ចូរគ្របស្នាមប្រេះតាមទ្វារ និងបង្អួចដោយបង់ស្អិតក្រណាត់ ឬកន្សែង ។
- បិទរាល់ប្រព័ន្ធសម្លេង និងត្រជាក់ទាំងអស់ដូចជា ម៉ាស៊ីនត្រជាក់ និងកង្ហារផ្សេងតាមបង្អួច ប្រសិនបើត្រូវបានណែនាំ ។
- ស្តាប់វិទ្យុក្នុងតំបន់ សម្រាប់ព័ត៌មានទាន់ហេតុការណ៍ ។
- ទុកសត្វចិញ្ចឹមរបស់អ្នកនៅជាមួយអ្នក ។
- ប្រសិនបើអ្នកមានភាពអាសន្នព្យាបាល ចូរទូរស័ព្ទទៅកាន់លេខ ៩-១-១ ដើម្បីឱ្យក្រសួងប៉ូលីស និងអគ្គីភ័យដឹងថាអ្នកត្រូវការជំនួយពិសេស ។
- រក្សាទូរស័ព្ទរបស់អ្នកឱ្យអាចទទួលបានការហៅភាពអាសន្ន។



## វត្ថុសម្រាប់ឧបករណ៍ជ្រកក្នុងកន្លែងមួយរបស់អ្នក



- ទឹកផឹកបីហ្គាឡុងក្នុងម្នាក់
- ចំណីអាហារដែលនឹងមិនងាយស្អុយរលួយ រៀបចំជាស្រេច ដើម្បីបរិភោគចំណីអាហារ
- ឧបករណ៍បើកកំប៉ុងដោយដៃ និងគ្រឿងប្រដាប់បរិភោគសម ស្លាបព្រា កាំបិត ចាន ពែង)
- បន្ទះប្លាស្ទិកដើម្បីគ្របបង្អួច កន្ត្រៃ និងបង់ស្អិតបិទបំពង់
- ឧបករណ៍ជំនួយបឋម
- ពិល និងថ្មពិលបន្ថែម
- វិទ្យុប្រើប្រាស់ថ្មពិល និងថ្មពិលបន្ថែម អ្នកក៏អាចទិញវិទ្យុដែលមិនប្រើថ្មពិលផងដែរ)
- ផ្លុំហួចជាសញ្ញាសុំជំនួយ
- ថ្នាំអ៊ីយ៉ូដ ឬថ្នាំសមិនក្រអូបចំនួនមួយភាគបួន និងថ្នាំដាក់ភ្នែក ទឹកដែលមិនឆ្លងរោគប៉ុណ្ណោះ ប្រសិនបើត្រូវបានណែនាំឱ្យធ្វើដូច្នេះដោយមន្ត្រីសុខភាព ។ ដើម្បីកុំឱ្យឆ្លងជាមួយថ្នាំ ចូរបន្ថែមថ្នាំស ៨ តំណក់ក្នុងទឹកមួយហ្គាឡុង)
- សម្ភារៈថែទាំផ្ទាល់ខ្លួន: សាប៊ូ ច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញ ផលិតផលស្ត្រី ក្រដាសអនាម័យ និងក្រណាត់សំអាត
- ទូរស័ព្ទដែលមិនត្រូវការប្រើភ្លើង គ្រាន់តែដោតទៅនឹងឧបករណ៍ដោយទូរស័ព្ទ)
- សម្ភារៈផ្គត់ផ្គង់ថែទាំកុមារ ឬសម្ភារៈថែទាំពិសេសផ្សេងទៀត

មន្ត្រីនឹងជូនដំណឹងអ្នកតាមវិទ្យុក្នុងតំបន់ នៅពេលភាពអាសន្នកន្លងផុតទៅ ។ មានតែពេលនោះប៉ុណ្ណោះ ដែលអ្នកត្រូវបើកទ្វារ និងបង្អួចទាំងអស់ ដើម្បីឱ្យមានខ្យល់បរិសុទ្ធចេញចូលក្នុងផ្ទះរបស់អ្នក ។